# ដំណឹងជ្រើសរើស យុវជនស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសយុវជនស្ម័គ្រចិត្តទាំងពីរភេទ**ច្រើននាក់**ឱ្យចូលរួមក្នុងគម្រោងស្តីពី៖ «**ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ តាមរយៈភាពជាអ្នកដឹកនាំរបស់យុវជនក្នុងសកម្មភាពស្ម័គ្រចិត្តសង្គម**» ដែលនឹងចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០២៥ តទៅ ដើម្បីទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

១) ការបណ្តុះបណ្តាលស្តីពី «**ភាពជាអ្នកដឹកនាំ គ្រប់គ្រង និងការប្រើប្រាស់ជំនាញទន់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈ, វិធីសាស្ត្រស្រាវជ្រាវ តាមរយៈការធ្វើសម្ភាស សរសេរសាច់រឿងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងថែរក្សាឯកសារប្រវត្តិសាស្ត្រ និងតួនាទីរបស់យុវជនក្នុងការគាំទ្រលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ**»។ វគ្គបណ្តុះបណ្តាលនីមួយៗ នឹងត្រូវធ្វើឡើងតាមប្រព័ន្ធអនឡាញ (Zoom Meeting) រយៈពេលមួយព្រឹក ឬមួយរសៀល។

២) ការចុះទៅធ្វើបទសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលស្ថិតនៅក្នុងភូមិឃុំជាមួយខ្លួន ដើម្បីស្តាប់សាច់រឿងជីវិត កត់ត្រាទុកអំពីសាច់រឿងទាំងនោះ និងពិភាក្សាអំពីប្រធានបទទាក់ទងនឹងតួនាទីរបស់យុវជនកម្ពុជានាពេលអនាគត។ ការចុះជួបជាមួយចាស់ៗ គឺជាការបង្កើនទំនាក់ទំនងអន្តរជំនាន់ និងសមត្ថភាពយុវជនក្នុងសង្គមកម្ពុជា។

៣) លទ្ធផលការងារជាមួយចាស់ៗ និងសកម្មភាពរបស់យុវជននៅតាមមូលដ្ឋាន នឹងត្រូវបោះពុម្ពនៅក្នុងសៀវភៅមគ្គុទ្ទេសស្តីពី «**ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ**» ដើម្បីជាមាគ៌ារបស់យុវជនជំនាន់ក្រោយក្នុងការអនុវត្តសកម្មភាពការងារសង្គមស៊ីវិលនៅកម្ពុជា និងផ្សព្វផ្សាយនៅក្នុងគេហទំព័រស្តីពី «**ការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់យុវជនតាមរយៈការងារស្ម័គ្រចិត្ត**»។

**ផលប្រយោជន៍ដែលយុវជនស្ម័គ្រចិត្តម្នាក់ៗទទួលបាន៖**

- ចំណេះដឹងទាក់ទងនឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងក្នុងការអភិវឌ្ឍវិជ្ជាជីវៈ, វិធីសាស្ត្រស្រាវជ្រាវ និងមាគ៌ាឆ្ពោះទៅការគោរពលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។
- ការឧបត្ថម្ភសោហ៊ុយធ្វើដំណើរសម្រាប់យុវជនស្ម័គ្រចិត្តម្នាក់ៗ ចុះទៅធ្វើសម្ភាសជាមួយអ្នករស់រានមានជីវិត។ **បញ្ជាក់៖** យុវជនស្ម័គ្រចិត្តម្នាក់ៗ អាចធ្វើសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចាប់ពី៦នាក់ឡើងទៅ។
- ចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមជ្រៅជ្រះជាងមុន និងការជឿជាក់សមត្ថភាពក្នុងការធ្វើទំនាក់ទំនងអន្តរជំនាន់ តាមរយៈការរៀនសូត្រពីកិច្ចការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។

**លក្ខខណ្ឌជ្រើសរើស៖**

- សិស្សបញ្ចប់ថ្នាក់ទី១២ និងនិស្សិតកំពុងសិក្សា ឬបញ្ចប់ការសិក្សាកម្រិតសាកលវិទ្យាល័យគ្រប់ជំនាញឯកទេស។
- មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចបាននូវលទ្ធផលការសិក្សា និងការងារគម្រោង រាប់ទាំងការធ្វើដំណើរទៅកាន់គោលដៅការងារ និងអត់ធ្មត់ខ្ពស់ចំពោះការងារនៅតាមមូលដ្ឋាន។
- មានក្រមសីលធម៌ និងអាកប្បកិរិយាថ្លៃថ្នូ។
- ចេះគោរព យកចិត្តទុកដាក់ និងមានទំនាក់ទំនងល្អជាមួយមនុស្សវ័យចំណាស់ និងអ្នកនៅជុំវិញខ្លួន។
- ចេះភាសាខ្មែរល្អប្រសើរ ទាំងការសរសេរ និងការប្រើប្រាស់អក្ខរាវិរុទ្ធនិងវេយ្យាករណ៍។
- មានចំណេះដឹងភាសាបរទេសខ្លះៗ។
- មានចំណេះដឹងក្នុងការប្រើប្រាស់ទូរសព្ទ ឬឧបករណ៍ផ្សេងៗ ដើម្បីថតសម្លេងសម្ភាស, ថតរូប ឬថតវីដេអូ, ផ្ទុកឯកសារនិងថែរក្សាឯកសារជាកិច្ចសម្ភាស, និងផ្ទេរឯកសារពីទូរសព្ទដៃ ឬឧបករណ៍មួយទៅឧបករណ៍មួយទៀត។
- មានភាពច្នៃប្រឌិតចំពោះកិច្ចការដែលទាក់ទងនិងគម្រោង។

**តួនាទី និងភារកិច្ច៖**

- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។
- ចុះធ្វើសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ពីប្រវត្តិ និងបទពិសោធន៍របស់គាត់។
- សង្ខេបសាច់រឿងរបស់អ្នករស់រានមានជីវិតដែលបានជួប រួចសរសេរសាច់រឿងទាំងនោះដើម្បីប្រើប្រាស់ជាឯកសារប្រវត្តិសាស្ត្រ និងផ្សព្វផ្សាយ។
- ពិភាក្សាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលអ្នកបានជួបពី «ការអភិវឌ្ឍសហគមន៍»។

ចំពោះសិស្ស/និស្សិតដែលចាប់អារម្មណ៍នឹងការសិក្សា និងការងារខាងលើ សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតចំណាប់អារម្មណ៍ មកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈបុគ្គលិក ឬ ប្រធានក្រុមអ្នកស្ម័គ្រចិត្តដែលបម្រើការនៅក្នុងគម្រោងនេះ ដូចមានរាយឈ្មោះខាងក្រោម ឬបំពេញទម្រង់ចុះឈ្មោះធ្វើជាយុវជនស្ម័គ្រចិត្ត តាមតំណភ្ជាប់ខាងក្រោម៖

https://forms.gle/6f8DBJe3LwFjJPBw5

**បុគ្គលិកទទួលបន្ទុកទទួលពាក្យ និងទំនាក់ទំនង៖**

- ដារ៉ាវដ្ឋ មេត្តា៖ ទូរសព្ទ និងតេឡេក្រាម៖ ០៧៨ ៦៩៨ ៣៣៣
- ធឹប ស្រីនិច្ច៖ ទូរសព្ទ និងតេឡេក្រាម៖ ០៨៧ ៣៥៦ ៧៦១
- ជឹម សុខគា៖ ទូរសព្ទ និងតេឡេក្រាម៖ ០១៥ ៩៦១ ៥២៧

*សូមអរគុណ!*